ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 16

# ទ្រព្យ រោងចក្រ និងបរិក្ខារ

## Property, Plant and Equipment

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៣៥៥៧៧

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង“ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ”នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ទី តាយី**

## គោលបំណង

១- គោលបំណងនៃស្តង់ដានេះ គឺរៀបរាប់ពីការអនុវត្តគណនេយ្យកម្ម សម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ ដូច្នេះហើយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុអាចញែកព័ត៌មានអំពីការវិនិយោគរបស់អង្គភាពក្នុងទ្រព្យរោងចក្រនិងបរិក្ខារ និងការផ្លាស់ប្តូរក្នុង ការវិនិយោគបែបនេះ។ បញ្ហាចំបងក្នុង គណនេយ្យកម្ម សម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ គឺជាការទទួលស្គាល់នៃទ្រព្យសកម្ម ការគណនាតម្លៃយោងរបស់គេ និងបន្ទុករំលស់ និងការខាតបង់ពីការធ្លាក់ថ្លៃ ដែលត្រូវទទួលស្គាល់ទាក់ទងនឹងពួកគេ។

## វិសាលភាព

**២- ស្តង់ដានេះ ត្រូវបានគេអនុវត្តក្នុងគណនេយ្យ សម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ លើកលែងតែនៅពេលស្តង់ដាមួយផ្សេងទៀត តម្រូវ ឬអនុញ្ញាតឱ្យមានការអនុវត្តគណនេយ្យកម្មខុសគ្នា។**

៣- ស្តង់ដានេះ មិនអនុវត្តចំពោះ ÷

ក- ទ្រព្យរោងចក្រ និងបរិក្ខារ ដែលត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ដោយយោង ស.រ.ហ.អ.ក ៥ *ទ្រព្យសកម្មរយៈពេលវែង ដែលរក្សាទុកសម្រាប់លក់ និង ប្រតិបត្តិការមិនបន្ត*។

ខ- ទ្រព្យសកម្មជីវសាស្ត្រ ដែលទាក់ទងទៅនឹងសកម្មភាពកសិកម្ម (មើល ស.គ.អ.ក ៤១ *កសិកម្ម*)។

គ- ការទទួលស្គាល់ និងការវាស់វែង នៃការរុករក និងវាយតម្លៃទ្រព្យសកម្ម (សូមមើល ស.រ.ហ.អ.ក ៦ *ការរុករកនិងការវាយតម្លៃធនធានរ៉ែ) ឬ*

ឃ- សិទ្ធិវិនិយោគលើធនធានរ៉ែ និង ការបម្រុងទុករ៉ែ ដូចជា ប្រេងឧស្ម័នធម្មជាតិ និងធនធានស្រដៀង ដែលមិនអាចកកើតឡើងវិញ ។

ទោះយ៉ាងណា ស្តង់ដានេះអនុវត្តចំពោះទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវបានប្រើដើម្បីអភិវឌ្ឍ ឬ ថែរក្សាទ្រព្យសកម្ម ដែលត្រូវបានរៀបរាប់ក្នុង (ខ)-(ឃ) ។

៤- ស្តង់ដាផ្សេងទៀតអាចតម្រូវឱ្យមានការទទួលស្គាល់ធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលផ្អែកលើវិធីសាស្ត្រ ដែលខុសពីវិធីសាស្ត្រនៅក្នុងស្តង់ដានេះ។ ឧទាហរណ៍ ស.គ.អ.ក ១៧ *ភតិសន្យា* តម្រូវឱ្យអង្គភាពវាយតម្លៃការទទួលស្គាល់ធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ បានធ្វើភតិសន្យាតាមមូលដ្ឋាននៃការផ្ទេរហានិភ័យនិងផលប្រយោជន៍។ ប៉ុន្តែទោះជាយ៉ាងណាក្នុងករណីបែបនេះ ទិដ្ឋភាពផ្សេងទៀតនៃគណនេយ្យកម្ម សម្រាប់ទ្រព្យសកម្មទាំងនេះ រួមបញ្ចូលរំលស់ គឺត្រូវបានរៀបរាប់ដោយស្តង់ដានេះ ។

៥ អង្គភាពដែលប្រើប្រាស់វិធីសាស្ត្រថ្លៃដើម សម្រាប់ទ្រព្យវិនិយោគ ដោយអនុលោមតាម ស.គ.អ.ក ៤០ នឹងត្រូវប្រើប្រាស់វិធីសាស្ត្រថ្លៃដើមក្នុងស្តង់ដានេះ។

## និយមន័យ

៦- វាក្យស័ព្ទខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងស្តង់ដានេះ ដោយមានន័យបញ្ជាក់:

*តម្លៃយោង* គឺទឹកប្រាក់ដែលទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ បន្ទាប់ពីកាត់កងនូវរំលស់បូកបន្ត និង ការខាតបង់ពីការធ្លាក់ចុះតម្លៃបូកបន្ត ។

*ថ្លៃដើម* គឺទឹកប្រាក់នៃសាច់ប្រាក់ ឬ សមមូលសាច់ប្រាក់ដែលបានបង់ ឬតម្លៃសមស្របនៃតម្លៃតបស្នងផ្សេងទៀតដែលត្រូវផ្តល់ ដើម្បីទិញទ្រព្យសកម្មនៅពេលការទិញ ឬនៅពេលសាងសង់ ឬអាចអនុវត្តបានទឹកប្រាក់ដែលបានបែងចែកទៅឲ្យ ទ្រព្យសកម្ម នោះនៅពេលទទួលស្គាល់ដំបូងតាមសេចក្តីតម្រូវជាក់លាក់នៃ ស.រ.ហ.អ.ក ផ្សេងទៀត ឧទាហរណ៍ ស.រ.ហ.អ.ក ២ *ការទូទាត់ដោយផ្អែកលើប័ណ្ណភាគហ៊ុន ។*

*ទឹកប្រាក់អាចរំលស់បាន:* **គឺថ្លៃដើមនៃទ្រព្យសកម្ម ឬ ទឹកប្រាក់ផ្សេងទៀតដែលជំនួសថ្លៃដើមដកតម្លៃកាកសំណល់ ។**

*រំលស់:* **គឺការបែងចែកជាប្រព័ន្ធនៃទឹកប្រាក់អាចរំលស់បាននៃទ្រព្យសកម្មលើអាយុកាលអាចប្រើប្រាស់បានរបស់វា ។**

*តម្លៃជាក់លាក់របស់អង្គភាព* **គឺតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ ដែលអង្គភាពរំពឹងទុកថានឹងកើតឡើងពីការបន្តប្រើប្រាស់ទ្រព្យសកម្ម និង ការលក់របស់របស់ទ្រព្យសកម្មនោះ នៅចុងអាយុកាលប្រើប្រាស់ ឬ រំពឹងទុកថា នឹងកើតឡើងនៅពេលទូទាត់បំណុល ។**

*តម្លៃសមស្រប* គឺជាទឹកប្រាក់សំរាប់ទ្រព្យសកម្មមួយដែលអាចត្រូវបានដោះដូររវាង ភាគីដែលមានឆន្ទៈ និងយល់ដឹងនៅក្នុងប្រតិបត្តិការបើកចំហរ ។

*ការខាតបង់ពីការធ្លាក់ចុះតម្លៃ* គឺទឹកប្រាក់តម្លៃយោងនៃទ្រព្យសកម្មលើសទឹកប្រាក់ ដែលអាចទទួល បានមកវិញបាន ។

*ទ្រព្យ រោងចក្រ និងបរិក្ខារ* គឺជាធាតុរូបី:

ក- ត្រូវបានរក្សាទុកសម្រាប់ប្រើក្នុងផលិតកម្ម ឬផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់ជួលឱ្យអ្នកដ៏ទៃ ឬសម្រាប់គោលបំណងរដ្ឋបាល ។

ខ- ត្រូវបានរំពឹងទុកថា

នឹងត្រូវបានប្រើប្រាស់ច្រើនជាងមួយការិយបរិច្ឆេទ ។

*ទឹកប្រាក់ដែលអាចទទួលបានមកវិញ* គឺជាតម្លៃធំជាងនៃតំលៃសមរម្យដកថ្លៃដើមលក់នៃទ្រព្យសកម្ម និងតម្លៃប្រើប្រាស់វា។

*តម្លៃកាកសំណល់* នៃទ្រព្យសកម្មមួយ គឺទឹកប្រាក់ដែលត្រូវបានប៉ាន់ស្មានដែលបច្ចុប្បន្នអង្គភាពមួយទទួលបាន ពីការលក់ទ្រព្យសកម្ម បន្ទាប់ពីកាត់កងថ្លៃដើមប៉ាន់ស្មាននៃការលក់ ប្រសិនបើទ្រព្យសកម្មអស់អាយុកាលហើយស្ថិតក្នុងលក្ខខណ្ឌដែលបានរំពឹងទុកនៅចុងអាយុកាលប្រើប្រាស់របស់វា ។ រយៈពេលប្រើប្រាស់គឺ ÷

ក- ការិយបរិច្ឆេទដែលទ្រព្យសកម្មត្រូវបានរំពឹងទុកថានឹងអាចប្រើបានសម្រាប់ដោយអង្គភាព ឬ

ខ- ចំនួនផលិតកម្ម ឬឯកត្តាប្រហាក់ប្រហែល ដែលត្រូវបានរំពឹងទុកថា នឹងទទួលបានពី ទ្រព្យសកម្មដោយអង្គភាព ។

## ការទទួលស្គាល់

៧- ថ្លៃដើមនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ប្រសិនបើ និងតែប្រសិនបើ÷

ក- វាប្រហែលជាថា អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត ដែលពាក់ព័ន្ធជាមួយនឹងធាតុនោះ និងហូរចូលមកក្នុងអង្គភាព ។

ខ- ថ្លៃដើមនៃធាតុនោះ អាចត្រូវបានវាស់វែងដោយជឿទុកចិត្តបាន។

៨- គ្រឿងបន្លាស់ និងបរិក្ខារសំរាប់ផ្តល់សេវាកម្ម ជាធម្មតាត្រូវបានកត់ត្រាជាសន្និធិ និងត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលប្រើ។ ទោះជាយ៉ាងណា គ្រឿងបន្លាស់សំខាន់ៗ និងបរិក្ខារបម្រុងមានលក្ខណៈជាទ្រព្យ រោងចក្រ និងបរិក្ខារនៅពេលអង្គភាពរំពឹងទុកថានឹងប្រើប្រាស់ពួកវាច្រើនជាងមួយការិយបរិច្ឆេទ។ ស្រដៀងគ្នាដែរប្រសិនបើគ្រឿងបន្លាស់និងបរិក្ខារសេវាកម្មអាចត្រូវបានប្រើក្នុងការភ្ជាប់ជាមួយទ្រព្យរោងចក្រ និងបរិក្ខារ ពួកវាក៏ត្រូវបានធ្វើគណនេយ្យកម្មជាទ្រព្យរោងចក្រនិងបរិក្ខារដែរ ។

៩- ស្តង់ដានេះ មិនរៀបរាប់ពីឯកតានៃការវាស់វែងសម្រាប់ការទទួលស្គាល់ពោលគឺថាអ្វីដែលរួមមានទ្រព្យរោងចក្រ និងបរិក្ខារ។ ហេតុដូច្នេះ ការវិនិច្ឆ័យត្រូវបានតម្រូវឲ្យមានក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់

ចំពោះ កាលៈទេសៈជាក់លាក់របស់អង្គភាព។ វាអាចសមស្រប ដើម្បីសរុបធាតុមិនសំខាន់មួយៗ ដូចជាមេពុម្ព ឧបករណ៍ និងពុម្ព និងដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យចំពោះតម្លៃសរុប។

១០- អង្គភាព វាយតម្លៃតាមគោលការណ៍ទទួលស្គាល់នេះ ចំពោះថ្លៃដើមទាំងអស់របស់ទ្រព្យ រោងចក្រ និងបរិក្ខារនៅពេលដែលថ្លៃដើមទាំងនោះ បានកើតឡើង ។ ថ្លៃដើមទាំងនេះ រួមបញ្ចូលនូវថ្លៃដើម ដែលបានកើតឡើងដំបូងនៅពេលទិញ ឬសាងសង់ធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារនិងថ្លៃដើមដែលបានកើតឡើងក្រោយៗមកទៀតដើម្បី បន្ថែមដើម្បីជំនួសផ្នែក ឬផ្តល់សេវាឱ្យវា។

## ថ្លៃដើមដំបូង

១១- ធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារអាចត្រូវបានទិញសម្រាប់ហេតុផលសុវត្ថិភាព ឬហេតុផលបរិស្ថាន។ ការទិញទ្រព្យរោងចក្រ និងបរិក្ខារបែបនេះ ទោះយ៉ាងណាមិនបង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ច ដោយផ្ទាល់ចំពោះធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារមានស្រាប់ជាក់លាក់ អាចចាំបាច់សម្រាប់អង្គភាព ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតពីទ្រព្យសកម្មផ្សេងទៀត ។ ទ្រព្យរោងចក្រ និងបរិក្ខារបែបនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទទួលស្គាល់ជាទ្រព្យសកម្ម ពីព្រោះទ្រព្យទាំងនេះអាចធ្វើឱ្យអង្គភាពបង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត ពីទ្រព្យសកម្មដែលទាក់ទង ឬបានច្រើនជាងនៅពេលដែលទ្រព្យទាំងនោះមិនទាន់បានទិញ។ ឧទាហរណ៍ រោងចក្រផលិតជាតិគីមី អាចតំឡើងដំណើរគ្រប់គ្រងសារធាតុគីមីថ្មី ដើម្បីបំពេញតាមសេចក្តីតំរូវផ្នែកបរិស្ថានសម្រាប់ការផលិត និងការស្តុកទុកនៃ សារធាតុគីមីដ៏គ្រោះថ្នាក់។ ការបង្កើនសមត្ថភាពគ្រឿងចក្រ

ពាក់ព័ន្ធ គឺត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ពីព្រោះបើមិនមានពួកវា អង្គភាពមិនអាចផលិត និងលក់សារធាតុគីមីបានឡើយ ។ ទោះយ៉ាងណា តម្លៃយោងនៃទ្រព្យសកម្មបែបនេះ និងទ្រព្យសកម្មពាក់ព័ន្ធ គឺត្រូវបាន ត្រួតពិនិត្យឡើងវិញពីការធ្លាក់ចុះតម្លៃ ដោយអនុលោមតាម ស.គ.អ.ក ៣៦ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម ។

## ថ្លៃដើមបន្តបន្ទាប់

១២- តាមគោលការណ៍ទទួលស្គាល់ក្នុងកថាខណ្ឌ ៧ អង្គភាពមួយ មិនទទួលស្គាល់តម្លៃយោងនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ អំពីថ្លៃដើមនៃសេវាប្រចាំថ្ងៃរបស់ធាតុនោះឡើយ ។ ជាងនេះថ្លៃដើមទាំងនោះត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលកើតឡើង។ ថ្លៃដើមនៃសេវាប្រចាំថ្ងៃ គឺជាថ្លៃដើមសេវាប្រចាំថ្ងៃគឺជាពលកម្ម និងអាចប្រើប្រាស់ជាចម្បង និងអាចរួមបញ្ចូលនូវថ្លៃដើមនៃផ្នែកតូចៗ។ គោលបំណងនៃចំណាយទាំងនេះ ជារឿយៗត្រូវបានចាត់ទុកថាជា "ចំណាយជួស ជុល និងថែទាំ" នៃធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារ ។

១៣- ផ្នែកនៃធាតុខ្លះនៃទ្រព្យរោងចក្រ និងបរិក្ខារអាចតម្រូវឱ្យមានជំនួសជាចន្លោះពេលថេរ ។ ឧទាហរណ៍ប្រព័ន្ធកំដៅអាចតម្រូវ ឱ្យប្តូរបន្ទាប់ពីចំនួនម៉ោងជាក់លាក់ ឬគ្រឿងខាងក្នុងយន្តហោះ ដូចជាកៅអីនិងបន្ទប់ធ្វើម្ហូបអាចតម្រូវឱ្យមាន ការជំនួស ច្រើនដង ក្នុងកំឡុងអាយុការនៃ យន្តហោះ ។ ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារក៏អាចត្រូវបានទិញដើម្បីកាត់ បន្ថយការជំនួសដែលកើតឡើងជាញឹកញាប់ ដូចជាជំនួសជញ្ជាំងខាងក្នុង នៃអគារ ឬធ្វើការជំនួសដែលមិនកើតឡើងម្តងទៀត។ តាមគោលការណ៍

ទទួលស្គាល់ក្នុងកថាខណ្ឌ ៧ អង្គភាពមួយ ទទួលស្គាល់តម្លៃយោងនៃទ្រព្យរោងចក្រ និងបរិក្ខារជាថ្លៃដើមនៃផ្នែកជំនួសនៃធាតុបែបនេះនៅពេលដែលថ្លៃដើមនោះបានកើតឡើងប្រសិនលក្ខណៈវិនិច្ឆ័យទទួលស្គាល់ត្រូវបានបំពេញ ។ តម្លៃយោងនៃផ្នែកទាំងនោះដែលត្រូវបានជំនួសត្រូវបានឈប់ទទួលស្គាល់វិញ ដោយអនុលោមតាមបញ្ញត្តិនៃការឈប់ទទួលស្គាល់នៃស្តង់ដានេះ (សូមមើលកថាខណ្ឌ ៦៧-៧២)។

១៤- លក្ខខណ្ឌនៃការបន្តប្រើធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ( ឧទាហរណ៍ យន្តហោះ ) អាចអនុវត្តការធ្វើអធិការកិច្ចចំបង ជាប្រចាំដោយមិនគិតថាតើផ្នែកនៃធាតុនោះត្រូវបានជំនួស ឬអត់នោះទេ។ នៅពេលការធ្វើអធិការកិច្ចចំបងនីមួយៗ ត្រូវបានអនុវត្ត ថ្លៃដើមរបស់វាត្រូវបានទទួលស្គាល់ក្នុងតម្លៃយោងនៃធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារនោះជាថ្លៃដើមជំនួសប្រសិនបើលក្ខណៈវិនិច្ឆ័យទទួលស្គាល់ត្រូវបានបំពេញ។ តម្លៃយោងនៅសល់មួយចំនួន នៃថ្លៃដើមសម្រាប់ការធ្វើអធិការកិច្ចគ្រាមុន (ដូចជាការខុសគ្នាពីផ្នែកជាក់ស្តែង) គឺត្រូវបានឈប់ទទួលស្គាល់ ។ នេះកើតឡើងដោយមិនគិតថា តើថ្លៃដើមនៃការធ្វើអធិការកិច្ចពីមុន ត្រូវបានកំណត់អត្តសញ្ញាណក្នុង ប្រតិបត្តិការ ដែលធាតុត្រូវបានទិញ ឬសាងសង់។ ប្រសិនបើចាំបាច់ថ្លៃដើមប៉ាន់ស្មាននៃការធ្វើអធិការកិច្ចស្រដៀងគ្នាអនាគតអាចត្រូវបានប្រើប្រាស់ដើម្បីប្រើជាការចង្អុលបង្ហាញអំពីថ្លៃដើមនៃ សមាសធាតុអធិការកិច្ចមានស្រាប់មានតំលៃប៉ុន្មាន នៅពេលធាតុនោះត្រូវបានទិញ ឬសាងសង់ ។

## ការវាស់វែងនៅពេលទទួលស្គាល់

១៥- ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារដែលបំពេញលក្ខណៈឱ្យការទទួលស្គាល់ជាទ្រព្យសកម្មត្រូវបានវាស់វែងជាថ្លៃដើម ។

**ធាតុនៃថ្លៃដើម**

១៦- ថ្លៃដើមនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខាររួមមាន ÷

ក- ថ្លៃទិញរបស់វា រួមមានពន្ធនាំចូល និងពន្ធលើការទិញមិនអាចបង្វិលមកវិញបានបន្ទាប់ពីកាត់កង អប្បហារពាណិជ្ជកម្ម និងប្រាក់បង្វិលសងវិញ។

ខ- ថ្លៃដើមមួយចំនួន ដែលទាក់ទងដោយផ្ទាល់ទៅនឹងការនាំទ្រព្យសកម្មឱ្យដល់ទីតាំង និងស្ថានភាពចាំបាច់ដើម្បីឱ្យវាអាចដំណើរការបានក្នុងលក្ខណៈតាមបំណងរបស់គណៈគ្រប់គ្រង ។

គ- ការប៉ាន់ស្មានដំបូង អំពីថ្លៃដើមនៃការរុះរើ និងការផ្លាស់ប្តូរទីតាំងទ្រព្យរោងចក្រ និងបរិក្ខារ និងរៀបឡើងវិញដែលវាត្រូវបានដាក់ទីតាំងបំណុលដែលអង្គភាពបានបង្កើតឡើងនៅពេលធាតុនោះត្រូវបានទិញ ឬដោយសារបានប្រើប្រាស់ធាតុនោះ ក្នុងកំឡុងការិយ-បរិច្ឆេទជាក់លាក់ សម្រាប់គោលបំណងក្រៅពីផលិតទំនិញក្នុងស្តុកក្នុងកំឡុងការិយបរិច្ឆេទនោះ ។

១៧ ឧទាហរណ៍ពីថ្លៃដើមដែលចូលរួមដោយផ្ទាល់ គឺ÷

(ក) ថ្លៃដើមនៃ អត្ថប្រយោជន៍និយោជិក (ដូចបានកំណត់នៅក្នុង ស.គ.អ.ក ១៩ *អត្ថប្រយោជន៍និយោជិក*) ដែលកើតឡើងដោយផ្ទាល់ពីការសាងសង់ឬទិញធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ

(ខ) ថ្លៃដើមនៃការរៀបចំទីតាំង

(គ) ថ្លៃដើមលើកដាក់និងថ្លៃដើមប្រគល់

(ឃ) ថ្លៃដើមតំឡើង និងផ្គុំ

(ង) ថ្លៃដើមធ្វើតេស្តថាតើទ្រព្យសកម្មបំពេញមុខងារបាន ត្រឹមត្រូវដែរឬទេ បន្ទាប់ពីការដកចេញចំណូលពិត ពីការលក់ធាតុណាមួយដែលបានផលិតនៅខណៈ ពេលនាំយកទ្រព្យសកម្មទៅកាន់ទីតាំង និងលក្ខខណ្ឌនោះ (ដូចជាសំណាកដែលបានផលិតនៅពេលធ្វើតេស្តបរិក្ខារ) និង

(ច) ថ្លៃសេវាអាជីព

១៨ អង្គភាពមួយអនុវត្ត ស.គ.អ.ក ២ *សន្និធិ* ចំពោះថ្លៃដើមនៃកាតព្វកិច្ចដើម្បីរុះរើ ផ្លាស់ចេញ និងស្តារឡើងទីតាំងឡើងវិញទៅលើធាតុ ដែលតាំងនៅដែលបានកើតឡើងក្នុងកំឡុងការិយបរិច្ឆេទជាក់លាក់ ជាវិបាកមួយនៃការប្រើប្រាស់ធាតុ ដើម្បីផលិតសន្និធិក្នុងកំឡុងការិយបរិច្ឆេទនោះ។ កាតព្វកិច្ចសំរាប់ថ្លៃដើមដែលបាន ធ្វើគណនេយ្យកម្មតាម ស.គ.អ.ក ២ ឬ ស.គ.អ.ក ១៦ ត្រូវបានទទួលស្គាល់ និងវាស់វែងដោយអនុលោមតាម ស.គ.អ.ក ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ។*

១៩- ឧទាហរណ៍នៃថ្លៃដើមដែលមិនមែនជាថ្លៃដើមនៃទ្រព្យ រោងចក្រ និងបរិក្ខារ គឺ ÷

ក- ថ្លៃដើមនៃការបើកការសម្របសម្រួលថ្មីមួយ។

ខ- ថ្លៃដើមនៃការណែនាំផលិតផល ឬ សេវាថ្មី (ដែលរួមមានថ្លៃដើម ផ្សាយពាណិជ្ជកម្ម និងសកម្មភាពផ្សព្វផ្សាយ។

គ- ថ្លៃដើមនៃការធ្វើពាណិជ្ជកម្ម ក្នុងទីតាំងថ្មីមួយ ឬជាមួយប្រភេទថ្មីនៃអតិថិជន (រួមមានថ្លៃ ដើមនៃការបង្ហឹកហាត់បុគ្គលិក) ។

ឃ- ចំណាយរដ្ឋបាល និងថ្លៃដើមប្រយោលទូទៅផ្សេងៗទៀត ។

២០- ការទទួលស្គាល់ថ្លៃដើមក្នុងតម្លៃយោង នៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានឈប់ទៅវិញនៅពេលធាតុនោះ ស្ថិតក្នុងទីតាំង និងស្ថានភាពចាំបាច់សម្រាប់ធ្វើឱ្យវាអាចដំណើរការតាមបំណងរបស់គណៈគ្រប់គ្រង ។ ហេតុដូច្នេះ ថ្លៃដើមដែលកើតឡើងក្នុងការប្រើប្រាស់ ឬ បញ្ចូលឡើងវិញនូវធាតុនោះ គឺមិនត្រូវបានដាក់ បញ្ចូលក្នុងតម្លៃយោងនៃទ្រព្យ រោងចក្រ និងបរិក្ខារនោះឡើយ។ ឧទាហរណ៍ ថ្លៃដើមខាងក្រោម គឺមិនត្រូវបានដាក់បញ្ចូលក្នុងតម្លៃយោងនៃទ្រព្យរោងចក្រ និងបរិក្ខារ គឺ÷

ក- ថ្លៃដើមដែលបានកើតឡើង នៅពេលធាតុនោះអាចដំណើរការបានតាមបំណងរបស់ គណៈគ្រប់គ្រង គ្រប់គ្រងបាននាំយកមកប្រើប្រាស់ ឬដំណើរការតិចជាងសមត្ថភាពទាំងស្រុង។

ខ- ការខាតបង់លើប្រតិបត្តិការដំបូង ដូចជាការខាតទាំងនោះដែលកើតឡើងខណៈពេលដែល តំរូវការលើសម្មិទ្ធផលនៃធាតុកើនឡើង

គ- ថ្លៃដើមនៃការផ្លាស់ប្តូរទីតាំង ឬការរៀបចំឡើងវិញនូវអាជីវកម្មរបស់អង្គភាពមួយផ្នែក ឬទាំងអស់ ។

២១- អាជីវកម្មមួយចំនួនកើតឡើង ដើម្បីភ្ជាប់ជាមួយនឹងការសាងសង់ ឬការអភិវឌ្ឍនៃទ្រព្យ រោងចក្រ និងបរិក្ខារ ប៉ុន្តែមិនចាំបាច់នាំធាតុមកដល់ទីតាំង និងស្ថានភាពចាំបាច់ ដែលអាចដំណើរការបានតាមបំណងរបស់គណៈគ្រប់គ្រង។ ដំណើរការបន្ទាប់បន្សំទាំងនេះ អាចកើតឡើងមុនពេល ឬក្នុងកំឡុងពេល សាងសង់ ឬសកម្មអភិវឌ្ឍន៍។ ឧទាហរណ៍

ចំណូលអាចរកបានតាមរយៈប្រើប្រាស់ ការដ្ឋានអាគារ ជាចំណតឡាន រហូតដល់ការសាងសង់ចាប់ផ្ដើម។ ពីព្រោះដំណើរការបន្ទាប់បន្សំ គឺមិនចាំបាច់នាំធាតុនោះដល់ទីតាំង និងស្ថានភាពចាំបាច់ ដើម្បីអាចដំណើរការតាមបំណងរបស់ អ្នកគ្រប់គ្រង ចំណូល និងចំណាយពាក់ព័ន្ធនៃដំណើរការបន្ទាប់បន្សំ គឺត្រូវបានទទួលស្គាល់ ក្នុងប្រាក់ចំណេញ ឬខាត និង ដាក់បញ្ចូលក្នុងចំណាត់ថ្នាក់រំពឹងទុករបស់ ពួកវានៃចំណូល និង ចំណាយ ។

២២- ថ្លៃដើមនៃទ្រព្យសកម្មដែលសាងសង់ដោយខ្លួនឯង ត្រូវបានគណនាដោយប្រើប្រាស់គោលការណ៍ដូចគ្នាទៅនឹងទ្រព្យសកម្មដែលទិញដែរ។ ប្រសិនបើអង្គភាព បង្កើតទ្រព្យសកម្មប្រហាក់ប្រហែល គ្នាសម្រាប់លក់ក្នុងសកម្មភាព ពាណិជ្ជកម្មធម្មតា ថ្លៃដើមនៃទ្រព្យសកម្មនោះ ជាធម្មតាដូចគ្នាទៅនឹងថ្លៃដើមនៃការសាងសង់ទ្រព្យសកម្មសម្រាប់លក់ (មើលស.គ.ក ២)។ ហេតុដូច្នេះ ប្រាក់ចំណេញ ខាងក្នុងមួយចំនួន ត្រូវបានលប់ចោល ដើម្បីទទួលបានថ្លៃដើមបែបនោះ ។ ស្រដៀងគ្នាដែរថ្លៃដើមនៃទឹកប្រាក់មិនធម្មតានៃការខ្ជះខ្ជាយវត្ថុធាតុដើម ពលកម្ម ឬធនធានផ្សេងៗទៀតដែលបានកើតឡើង ក្នុងការសាងសង់ទ្រព្យសកម្មដោយខ្លួនឯង គឺមិនត្រូវបានដាក់បញ្ចូលក្នុងថ្លៃដើមទ្រព្យ រោងចក្រ និងបរិក្ខារឡើយ។ ស.គ.ក ២៣ បន្ទុកប្រាក់កម្ចី បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ការប្រាក់ ជាសមាសធាតុមួយនៃតម្លៃយោងនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលសាងសង់ដោយខ្លួនឯង ។

**ការវាស់វែងថ្លៃដើម**

២៣- ថ្លៃដើមនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ គឺតំលៃសមមូលជាសាច់ប្រាក់នៅកាលបរិច្ឆេទទទួលស្គាល់។ ប្រសិនបើ ការទូទាត់ត្រូវបាន ពន្យារហួសរយៈពេលឥណទានធម្មតា នោះភាពខុសគ្នារវាងតំលៃសមមូល ជាសាច់ប្រាក់ និងការទូទាត់សរុប ត្រូវបានទទួលស្គាល់ ជាការប្រាក់លើការិយ-បរិច្ឆេទនៃឥណទាន លើកលែងតែការប្រាក់ បែបនេះ ត្រូវបានធ្វើមូលធន-កម្មដោយអនុលោមតាម ស.គ.ក ២៣ ។

២៤- ធាតុមួយឬច្រើននៃទ្រព្យ រោងចក្រ និងបរិក្ខារអាចត្រូវបានទិញ ក្នុងដោះដូរសំរាប់ទ្រព្យសកម្មមិនមែនរូបិយវត្ថុ ទ្រព្យសកម្ម ឬរួមបញ្ចូលទាំងរូបិយវត្ថុ និងទ្រព្យសកម្មមិនមែនជារូបិយវត្ថុ ។ ការពិភាក្សាខាងក្រោមជាធម្មតាសំដៅដល់ការ ដោះដូរទ្រព្យ សកម្មមិនមែនជារូបិយវត្ថុ សម្រាប់ទ្រព្យសកម្មមួយផ្សេងទៀត ប៉ុន្តែវាក៏អនុវត្តចំពោះការប្តូរទាំងអស់ ដែលរៀបរាប់ក្នុងប្រយោគមុនៗ ។ ថ្លៃដើមនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារបែបនេះ គឺត្រូវបានវាស់វែងជាតម្លៃសមស្របលើកលែងតែ (ក) ប្រតិបត្តិ-ការដោះដូរខ្វះលក្ខណះពិតពាណិជ្ជកម្មឬ(ខ)តម្លៃសមស្របនៃទ្រព្យសកម្មដែលទទួលបាន ឬទ្រព្យសកម្មដែលបោះបង់ គឺមិនអាចវាស់វែងដោយជឿទុកចិត្តបាន។ ធាតុដែលត្រូវទិញ គឺត្រូវបានវាស់វែងតាមវិធីនេះ ទោះជាអង្គភាព មិនអាចឈប់ទទួលស្គាល់ភ្លាមៗ នូវទ្រព្យសកម្មដែលត្រូវបានបោះបង់។ ប្រសិនបើធាតុដែលត្រូវទិញ គឺមិនត្រូវបានវាស់វែងតាមតម្លៃសមស្របថ្លៃដើមរបស់វា គឺត្រូវបានវាស់វែងតាមតម្លៃយោងនៃទ្រព្យសកម្មដែលត្រូវបានបោះបង់ ។

២៥- អង្គភាព កំណត់ថា តើប្រតិបត្តិការដោះដូរមានលក្ខណៈពាណិជ្ជកម្ម ដោយគិតពីទំហំដែលលំហូរសាច់ប្រាក់ អនាគតរបស់វាត្រូវបានរំពឹងទុកផ្លាស់ប្តូរដោយសារតែប្រតិបត្តិការ។ ប្រតិបត្តិការប្តូរ មានលក្ខណៈពាណិជ្ជកម្ម ប្រសិនបើ ÷

ក- រូបសណ្ឋាន (ហានិភ័យពេលវេលា និងទឹកប្រាក់) នៃលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានទទួលខុសគ្នាពីគំរូនៃលំហូរនៃទ្រព្យសកម្មដែលត្រូវផ្ទេរ ឬ

ខ- តម្លៃជាក់លាក់របស់អង្គភាពនៃផ្នែកអាជីវកម្មរបស់អង្គភាព ដែលជះឥទ្ធិពលដោយការ ប្រែប្រួលប្រតិបត្តិការដោយសារតែការដោះដូរ និង

គ- ភាពខុសគ្នាក្នុង (ក) ឬ (ខ) គឺទាក់ទងគ្នាយ៉ាងខ្លាំងទៅនឹងតម្លៃសមស្របនៃទ្រព្យសកម្ម ដែលបានដោះដូរ ។

សម្រាប់គោលបំណងនៃការកំណត់ ថាតើប្រតិបត្តិការដោះដូរមានលក្ខណៈពាណិជ្ជកម្ម នោះតម្លៃអង្គភាពជាក់លាក់ នៃផ្នែកអាជីវកម្មរបស់អង្គភាពដែលរងឥទ្ធិពលដោយប្រតិបត្តិ ត្រូវឆ្លុះបញ្ចាំងលំហូរសាច់ប្រាក់ក្រោយបង់ពន្ធ។ លទ្ធផលនៃការវិភាគទាំងនេះអាចច្បាស់លាស់ដោយមិនមានអង្គភាពត្រូវអនុវត្តការគណនាលំអិត ។

២៦- តម្លៃសមស្របនៃទ្រព្យសកម្ម ប្រតិបត្តិការទីផ្សារអាចប្រៀបធៀបបានមិនកើតមានអាចវាស់វែងដោយជឿទុកចិត្តបានប្រសិនបើ (ក) ភាពប្រែប្រួលក្នុងការប៉ាន់ស្មានតម្លៃសមស្រប គឺមិនសំខាន់សម្រាប់ទ្រព្យសកម្មនោះ ឬ (ខ) ភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗគ្នានៅក្នុងប្រភេទនោះ អាចត្រូវបានវាយតម្លៃដោយសមហេតុផល និងត្រូវបានប្រើប្រាស់ ដើម្បីវាស់វែង

ថ្លៃដើមនៃទ្រព្យសកម្មដែលបានទទួល លើកលែងតែតម្លៃសមស្របនៃទ្រព្យសកម្ម ដែលបានទទួល មានភស្តុតាងច្បាស់លាស់ច្រើនជាង ។

២៧- ថ្លៃដើមនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលរក្សាទុកដោយភតិកៈតាមភតិសន្យាហិរញ្ញវត្ថុ គឺត្រូវបានកំណត់តាម ស.គ.អ.ក ១៧ ។

២៨- តម្លៃយោងនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ អាចត្រូវបានកាត់បន្ថយដោយជំនួយរដ្ឋាភិបាលតាម ស.គ.អ.ក ២០ *គណនេយ្យសម្រាប់អំណោយរដ្ឋាភិបាល និង ការលាតត្រដាងពីជំនួយរបស់រដ្ឋាភិបាល។*

## ការវាស់វែងបន្ទាប់ពីការទទួលស្គាល់

២៩- អង្គភាពមួយ ត្រូវជ្រើសរើសវិធីសាស្ត្រថ្លៃដើមក្នុងកថាខណ្ឌ ៣០ ឬ វិធីសាស្ត្រវាយតម្លៃឡើងវិញក្នុង កថាខណ្ឌ ៣១ ជាគោលនយោបាយគណនេយ្យរបស់គេ ហើយត្រូវអនុវត្តគោលនយោបាយនោះ ចំពោះថ្នាក់ទាំងមូលនៃទ្រព្យ រោងចក្រ និងបរិក្ខារ ។

### វិធីសាស្ត្រថ្លៃដើម

៣០- បន្ទាប់ពីការទទួលស្គាល់ជាទ្រព្យសកម្ម ជាធាតុមួយនៃ ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវកត់ត្រាតាមថ្លៃដើមរបស់វាដករំលស់បូកបន្ត និងការខាតពីការធ្លាក់ចុះតម្លៃ ។

**វិធីសាស្ត្រវាយតម្លៃឡើងវិញ**

៣១- **បន្ទាប់ពីទទួលស្គាល់ជាទ្រព្យសកម្ម (ធាតុមួយនៃទ្រព្យ រោងចក្រ និង បរិក្ខារ) ដែលតម្លៃសមស្របរបស់វាត្រូវបានវាស់វែង ដោយជឿទុកចិត្ត បានត្រូវបានបង្ហាញជាទឹកប្រាក់តាមម្លៃទឹកប្រាក់វាយតម្លៃឡើងវិញ ជាតម្លៃ សមស្រប នៅថ្ងៃនៃការវាយតម្លៃឡើងវិញ ដករំលស់បូកបន្ត និងការខាត បង់បូកបន្តក្រោយៗទៀត។ ការវាយតម្លៃឡើងវិញត្រូវបានគេធ្វើឡើងយ៉ាង ទៀតទាត់ ដើម្បីធានាថា តម្លៃយោងមិនខុសគ្នាជាសារវ័ន្តពីតម្លៃដែលត្រូវ បានគណនាដោយប្រើប្រាស់តម្លៃសមស្រប នៅការិយបរិច្ឆេទរាយការណ៍ នោះទេ។**

៣២- តម្លៃសមស្របនៃដី និងអគារជាធម្មតាត្រូវបានកំណត់ពីភស្តុតាង ដែល បានមកពីទីផ្សារដោយការវាយតម្លៃ ជាធម្មតាធ្វើឡើងដោយអ្នកវាយតម្លៃ មានវិជ្ជាជីវៈ។ តម្លៃសមស្របនៃធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារ ជាធម្មតា គឺជាតម្លៃសមស្របដែលត្រូវបានកំណត់ដោយការវាយតម្លៃ។

៣៣- ប្រសិនបើ គ្មានភស្តុតាងពីទីផ្សារនៃតម្លៃសមស្រប ពីព្រោះតែលក្ខណៈ ពិសេសនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ និងធាតុនោះកម្រត្រូវ បានលក់ លើកលែងជាផ្នែកមួយនៃអាជីវកម្មកំពុងបន្ត អង្គភាព អាចត្រូវ ការប៉ាន់ស្មានតម្លៃសមស្រប ដោយប្រើប្រាស់ចំណូល ឬវិធីសាស្ត្រថ្លៃដើម ជំនួសដែលដករំលស់រួច។

៣៤- ភាពញឹកញាប់នៃការវាយតម្លៃឡើងវិញ អាស្រ័យលើការប្រែប្រួលក្នុងតម្លៃ សមស្របនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារដែល ត្រូវបាន ធ្វើរំលស់។ នៅពេលតម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវបានវាយតម្លៃរួច

ខុសពីតម្លៃយោងរបស់វាជាសារវ័ន្តការវាយតម្លៃបន្ថែមទៀតត្រូវបានតម្រូវឱ្យមាន។ ធាតុមួយចំនួននៃទ្រព្យ រោងចក្រ និងបរិក្ខារ មានការប្រែប្រួលយ៉ាងខ្លាំងក្នុងតម្លៃសមស្របរបស់វា ហេតុដូច្នេះ ចាំបាច់ត្រូវធ្វើការវាយតម្លៃឡើងវិញជាប្រចាំឆ្នាំ។ ការវាយតម្លៃឡើងវិញជាញឹកញាប់បែបនេះគឺមិនចាំបាច់សម្រាប់ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារដែលមានការប្រែប្រួលមិនខ្លាំងក្លាក្នុងតម្លៃសមស្របទេ។ ជាការពិតវាអាចចាំបាច់ដើម្បីវាយតម្លៃធាតុនោះរាល់ ៣ ឬ ៥ ឆ្នាំម្តងបានហើយ ។

៣៥- នៅពេលធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារត្រូវបានវាយតម្លៃឡើងវិញនោះ រំលស់បូកបន្តនៅកាលបរិច្ឆេទវាយតម្លៃឡើងវិញត្រូវបានចាត់ទុកជាមធ្យោបាយមួយក្នុងមធ្យោបាយខាងក្រោមៈ

ក- បានបង្ហាញឡើងវិញតាមសមាមាត្រជាមួយនឹងការប្រែប្រួលក្នុងតម្លៃយោងដុលនៃ ទ្រព្យសកម្ម ដូច្នេះតម្លៃយោងនៃទ្រព្យសកម្មបន្ទាប់ពីការវាយតម្លៃឡើងវិញ ស្មើនឹងទឹកប្រាក់ ដែលត្រូវបានវាយតម្លៃឡើងវិញរបស់វា។ វិធីសាស្ត្រនេះ ជារឿយៗត្រូវបានប្រើប្រាស់នៅពេលទ្រព្យសកម្ម ត្រូវបានវាយតម្លៃតាមមធ្យោបាយដោយអនុវត្តសន្ទស្សន៍ ដើម្បីកំណត់ថ្លៃដើមជំនួសដករំលស់រួចរបស់ ។

ខ- បានលុបចោលទល់ និងតម្លៃយោងដុលនៃទ្រព្យសកម្ម និងទឹកប្រាក់ពិតដែលត្រូវបានបង្ហាញឡើងវិញចំពោះទឹកប្រាក់ ដែលបានវាយតម្លៃឡើងវិញនៃទ្រព្យសកម្ម។ វិធីសាស្ត្រនេះ ជារឿយៗត្រូវបានប្រើប្រាស់សម្រាប់អគារ ។

ទឹកប្រាក់នៃការកែសំរួលដែលកើតឡើងលើការបង្ហាញឡើងវិញ ឬ ការលុបចោលនៃរំលស់បូកបន្ត បង្កើតបានជាផ្នែក នៃការកើតឡើង ឬថយចុះក្នុងតម្លៃយោង ដែលត្រូវបានធ្វើគណនេយ្យកម្ម តាមកថាខណ្ឌ ៣៩ និង ៤០។

**៣៦- ប្រសិនបើធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានវាយតម្លៃឡើងវិញ ថ្នាក់ទាំងមូលនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលទ្រព្យសកម្ម នឹងត្រូវបានវាយតម្លៃឡើងវិញ។**

៣៧- ថ្នាក់មួយនៃទ្រព្យ រោងចក្រ និង បរិក្ខារ គឺជាក្រុមនៃទ្រព្យសកម្ម ដែលមានលក្ខណៈ និង ការប្រើប្រាស់ប្រហាក់ប្រហែលគ្នា ក្នុងកិច្ចប្រតិបត្តិការរបស់អង្គភាព ។ ខាងក្រោម គឺជាឧទាហរណ៍នៃថ្នាក់ដាច់ដោយឡែក ÷

ក- ដី

ខ- ដី និង អគារ

គ- ម៉ាស៊ីន

ឃ- កប៉ាល់

ង- យន្តហោះ

ច- យានយន្ត

ឆ- គ្រឿងសង្ហារឹម និងអសង្ហារឹម

ជ- បរិក្ខារការិយាល័យ

៣៨- ធាតុក្នុងថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានវាយតម្លៃនៅពេលទន្ទឹមគ្នា ដើម្បីជៀសវាងការវាយតម្លៃឡើងវិញនៃទ្រព្យសកម្ម និងការរាយ-ការណ៍ ទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលជាការបញ្ចូលគ្នានៃថ្លៃដើម និងតម្លៃនៅកាលបរិច្ឆេទខុសគ្នា។ ទោះជាយ៉ាងណាថ្នាក់មួយនៃទ្រព្យ រោងចក្រ និងបរិក្ខារអាចត្រូវបានវាយតម្លៃ តាមមូលដ្ឋានវិកិលដែលត្រូវ

បានផ្តល់ឱ្យការវាយតម្លៃឡើងវិញ នៃថ្នាក់ទ្រព្យសកម្មត្រូវបានបំពេញនៅក្នុងការិយបរិច្ឆេទខ្លី និងបាន ផ្តល់ការវាយតម្លៃនោះដែលត្រូវបានរក្សាទុកឱ្យទាន់សម័យ ។

៣៩- ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មត្រូវបានកើនឡើង ដោយសារការវាយតម្លៃឡើងវិញនោះ ការកើនឡើង ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀត និងប្ញកបន្តនៅក្នុងផ្នែកមូលនិធិក្រោមចំណងជើងថាទឹកប្រាក់អតិរេកពីការ វាយតម្លៃឡើងវិញ។ ទោះជាយ៉ាងណាការកើនឡើងត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត រហូតដល់ការកើនឡើងនោះបញ្ច្រាស់ការធ្លាក់ចុះ ពីការវាយតំលៃនៃទ្រព្យសកម្មដូចគ្នាដែលមានទទួលស្គាល់ពីមុននៅក្នុងរបាយការណ៍ចំណេញឬខាត ។

៤០- ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ត្រូវបានបន្ថយដោយសារតែការវាយតម្លៃឡើងវិញការថយចុះនោះ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។ ទោះយ៉ាងណាការថយចុះទទួលស្គាល់នៅក្នុងរបាយ-ការណ៍លទ្ធផលលម្អិតផ្សេងទៀត រហូតដល់សមតុល្យខាងឥណទានដែលមានស្រាប់នៅក្នុងទឹកប្រាក់អតិរេកពីការវាយតំលៃទាក់ទិននឹងទ្រព្យសកម្មនោះ។ ការថយចុះដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ លទ្ធផលលម្អិតផ្សេងទៀត កាត់បន្ថយទឹកប្រាក់ដែលបានប្ញកបន្តនៅក្នុងគណនីមូលធនក្រោមចំណងជើងថាទឹកប្រាក់អតិរេកពីការវាយតំលៃ ។

៤១- ទឹកប្រាក់អតិរេកពីការវាយតម្លៃឡើងវិញដែលរួមបញ្ចូលក្នុងគណនីមូលធនដែលទាក់ទងទៅនឹងធាតុ មួយនៃទ្រព្យ រោងចក្រ និងបរិក្ខារអាច ត្រូវបានផ្ទេរដោយផ្ទាល់ទៅគណនីប្រាក់ចំណេញរក្សាទុកនៅពេលដែល ទ្រព្យសកម្មនោះត្រូវឈប់ទទួលស្គាល់ ។ នេះអាចពាក់ព័ន្ធនឹងការផ្ទេរផ្នែកទាំងអស់នៃ

ទឹកប្រាក់អតិរេកនៅពេលដែលទ្រព្យសកម្មត្រូវបានលុបចោលឬលក់ចេញ។ ទោះយ៉ាងណា ទឹកប្រាក់អតិរេកមួយចំនួន អាចត្រូវបានផ្ទេរជាទ្រព្យសកម្មដែលត្រូវបានប្រើដោយអង្គភាពមួយ។ នៅក្នុងករណីបែបនេះ ទឹកប្រាក់នៃអតិរេកដែលបានផ្ទេរនឹងជាភាពខុសគ្នារវាងរំលស់ ដែលផ្អែកលើតម្លៃយោងវាយតម្លៃឡើងវិញរួចនៃទ្រព្យសកម្ម និង រំលស់ដែលផ្អែកលើថ្លៃដើមដំបូងរបស់ទ្រព្យសកម្ម។ ការផ្ទេរពីទឹកប្រាក់អតិរេកពី ការវាយតម្លៃឡើងវិញទៅគណនីប្រាក់ចំណេញរក្សាទុកគឺមិនត្រូវបានធ្វើឡើងតាមរយៈរបាយ-ការណ៍ចំណេញ ឬខាតឡើយ ។

៤២- ផលប៉ះពាល់នៃពន្ធលើប្រាក់ចំណូល ប្រសិនបើមានកើតឡើងពីការវាយតម្លៃឡើងវិញនៃទ្រព្យរោងចក្រ និងបរិក្ខារ ត្រូវបានគេទទួលស្គាល់ និងលាតត្រដាងបង្ហាញដោយអនុលោម ស.គ.អ.ក ១២ *ពន្ធប្រាក់ចំណូល* ។

## រំលស់

៤៣- ផ្នែកនីមួយៗនៃធាតុទ្រព្យរោងចក្រ និងបរិក្ខារជាមួយថ្លៃដើមដែលសំខាន់ក្នុងការពាក់ព័ន្ធទៅនឹងថ្លៃដើមសរុបនៃធាតុ នោះត្រូវបានធ្វើរំលស់ដាច់ដោយឡែក ។

៤៤- អង្គភាពមួយ បែងចែកទឹកប្រាក់ដែលត្រូវបានទទួលស្គាល់លើកដំបូងទាក់ទងទៅនឹងធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារទៅផ្នែកសំខាន់របស់វា និង រំលស់ដាច់ដោយឡែកនូវផ្នែកនីមួយៗបែបនេះ។ ឧទាហរណ៍ វាអាចសមស្រប ដើម្បីធ្វើរំលស់ដាច់ដោយឡែកនូវតួយន្តហោះ និងម៉ាស៊ីនយន្តហោះ ថាតើបានកាន់កាប់ ឬជាកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុ វាអាចសមស្របដើម្បីរំលស់ទឹកប្រាក់ដាច់ដោយឡែកដែលបាន ឆ្លុះនៅក្នុងថ្លៃដើមនៃ

ធាតុនោះ ដែលត្រូវបានបែងចែកទៅលក្ខខណ្ឌភតិសន្យាល្អ ឬមិនល្អដែលទាក់ទងនឹងលក្ខខណ្ឌទីផ្សារ ។

៤៥- ផ្នែកសំខាន់មួយនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ អាចមាន អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ដែលដូចគ្នាទៅនឹងអាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ នៃផ្នែកសំខាន់មួយផ្សេងទៀតនៃធាតុដូចគ្នា។ ផ្នែកបែបនេះ អាចត្រូវបានដាក់ជាក្រុមដើម្បីកំណត់ពីចំណាយរំលស់ ។

៤៦- ដរាបណាអង្គភាពរំលស់ដាច់ដោយឡែកនូវ ផ្នែកមួយចំនួននៃធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារ វាក៏ធ្វើរំលស់ដាច់ដោយឡែកនូវ ផ្នែកនៅសល់នៃធាតុនោះដែរ។ ផ្នែកនៅសល់ រួមមានផ្នែកនៃធាតុនោះ ដែលផ្នែកមួយមិនសំខាន់។ ប្រសិនបើអង្គភាព មានការរំពឹងទុកខុសគ្នាលើផ្នែកទាំងនោះ បច្ចេកទេសប្រហែលអាចចាំបាច់ដើម្បី ធ្វើរំលស់ផ្នែនៅសល់តាមលក្ខណៈដែលតំណាងឲ្យវិធីសាស្ត្រប្រើប្រាស់ត្រឹមត្រូវ និង/ឬអាយុកាលប្រើប្រាស់នៃផ្នែកនោះ ។

៤៧- អង្គភាព អាចជ្រើសរើសធ្វើរំលស់ដាច់ដោយឡែកនូវផ្នែកនៃធាតុនោះ ដែលមិនមានថ្លៃដើម គឺថាវាមានភាពសំខាន់ទាក់ទងទៅនឹងថ្លៃដើមសរុបនៃធាតុនោះ ។

**៤៨- បន្ទុករំលស់សម្រាប់ការិយបរិច្ឆេទនីមួយៗ ត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតលើកលែងបន្ទុករំលស់ត្រូវបានដាក់បញ្ចូលក្នុងតម្លៃយោង នៃទ្រព្យសកម្មមួយផ្សេងទៀត ។**

៤៩- បន្ទុករំលស់សម្រាប់ការិយបរិច្ឆេទជាធម្មតាត្រូវបានទទួលស្គាល់ក្នុងរបាយ-ការណ៍ចំណេញឬខាត។ ទោះជាយ៉ាងណាជួនកាលអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលមាននៅក្នុងទ្រព្យសកម្ម គឺត្រូវបានដាក់បញ្ចូលក្នុងការផលិត

ទ្រព្យសកម្មផ្សេងទៀត។ នៅក្នុងករណីនេះការបង្កើតជាផ្នែកនៃថ្លៃដើមនៃទ្រព្យសកម្ម ផ្សេងទៀត និងត្រូវបានដាក់បញ្ចូលនៅក្នុងតំលៃយោង។ ឧទាហរណ៍ រំលស់នៃទ្រព្យរោងចក្រ និងបរិក្ខាររោងចក្រដែលត្រូវបានប្រើសំរាប់សកម្មភាពអភិវឌ្ឍន៍អាចត្រូវបានដាក់បញ្ចូលនៅក្នុងថ្លៃដើមនៃទ្រព្យសកម្មអរូបិយដែលត្រូវបានទទួលស្គាល់ដោយអនុលោមតាម ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបិយ*។

## ទឹកប្រាក់អាចរំលស់បាន និងការិយបរិច្ឆេទរំលស់

៥០- ទឹកប្រាក់អាចរំលស់បាន នៃទ្រព្យសកម្មត្រូវបានបែងចែកតាមមូលដ្ឋានជាប្រព័ន្ធ លើអាយុកាលប្រើប្រាស់របស់វា។

**៥១- តម្លៃកាកសំណល់ និងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម ត្រូវបានពិនិត្យមើលឡើងវិញយ៉ាងហោចណាស់រាល់ចុងឆ្នាំងហិរញ្ញវត្ថុនីមួយៗ និងប្រសិនបើការរំពឹងទុកខុសពីការប៉ាន់ស្មានគ្រាមុន នោះការប្រែប្រួល ត្រូវបានគេធ្វើគណនេយ្យកម្មសម្រាប់ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានគណនេយ្យ ដោយអនុលោមតាម ស.គ.អ.ក ៨** *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង*។

៥២- រំលស់គឺត្រូវបានទទួលស្គាល់ ទោះបីជាតម្លៃសមស្របនៃទ្រព្យសកម្មលើសតម្លៃយោងរបស់ វាក៏ដោយដរាបណាតម្លៃកាកសំណល់នៃទ្រព្យសកម្មមិនលើសតម្លៃយោងរបស់វា។ ចំណាយជួសជុល និងថែទាំនៃទ្រព្យសកម្ម មិនផ្ទុយពីតម្រូវការចំពោះរំលស់វាឡើយ ។

៥៣- ទឹកប្រាក់អាចរំលស់បាននៃទ្រព្យសកម្ម គឺត្រូវបានកំណត់បន្ទាប់ពីកាត់កងតម្លៃកាកសំណល់របស់វា។ ក្នុងការអនុវត្តតម្លៃកាកសំណល់នៃទ្រព្យសកម្មជារឿយៗមិនភាពសំខាន់ទេ ហើយជាភាពមិនសារវ័ន្តក្នុងការគណនាទឹកប្រាក់អាចរំលស់បាន ។

៥៤- តម្លៃកាកសំណល់នៃទ្រព្យសកម្មមួយ អាចកើនឡើងដល់ទឹកប្រាក់ដែលស្មើនឹង ឬច្រើនជាងតម្លៃយោងនៃទ្រព្យសកម្ម។ ប្រសិនបើវា ដូច្នេះមែនបន្ទុករំលស់នៃទ្រព្យសកម្មឲ្យស្មើនឹងសូន្យ លើកលែងតែ និងរហូតដល់តម្លៃកាកសំណល់របស់វា ក្រោយមកថយចុះរហូតដល់មានទឹកប្រាក់ក្រោមតម្លៃយោងនៃទ្រព្យសកម្ម ។

៥៥- រំលស់នៃទ្រព្យសកម្មចាប់ផ្តើមនៅពេលទ្រព្យសកម្មអាចប្រើបាន ពោលគឺថានៅពេលទ្រព្យសកម្មស្ថិតក្នុងទីតាំងនិងលក្ខខណ្ឌដំណើរការតាមបំណងរបស់គណៈគ្រប់គ្រង។ រំលស់នៃទ្រព្យសកម្មមួយត្រូវបានបញ្ឈប់នៅដើមកាលបរិច្ឆេទ ដែលទ្រព្យសកម្មនោះ ត្រូវបានចាត់ទុកសម្រាប់លក់ (ឬដែលត្រូវបានដាក់បញ្ចូលក្នុងបណ្តុំក្រុមហ៊ុនលក់ចោលដែលត្រូវចាត់ថ្នាក់សម្រាប់លក់ ) តាម ស.រ.ហ.អ.ក ៥ និងកាលបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានឈប់ទទួលស្គាល់។ ហេតុដូច្នេះហើយការធ្វើរំលស់មិនឈប់ទេ នៅពេលទ្រព្យសកម្មទុកនៅឲ្យនៅទំនេរ ឬត្រូវបានដកចេញពីការប្រើប្រាស់ លើកលែងតែទ្រព្យសកម្មនោះ ត្រូវបានរំលស់អស់ទាំងស្រុង។ ទោះយ៉ាងណា តាមវិធីប្រើប្រាស់រំលស់កំពុងប្រើបន្ទុករំលស់រំលស់អាចស្មើនឹងសូន្យនៅពេលមិនផលិតកម្ម ។

៥៦- អត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត ដែលមានក្នុងទ្រព្យសកម្ម ត្រូវបានប្រើប្រាស់ដោយអង្គភាពមួយជាសំខាន់តាមរយៈការប្រើប្រាស់របស់វា ។ ទោះ

យ៉ាងណាកត្តាផ្សេងទៀត ដូចជាភាពហួសសម័យនៃបច្ចេកវិទ្យា ឬពាណិជ្ជកម្ម និងការខូចខាតនៅពេលទ្រព្យសកម្មនៅទំនេរជារឿយៗ នាំឱ្យមានការថយចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលអាចទទួលបានពីទ្រព្យសកម្មនោះ។ ហេតុដូច្នេះហើយ កត្តាខាងក្រោមទាំងអស់ គឺត្រូវបានគេពិចារណាក្នុងការកំណត់ពីអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មៈ

ក- ការប្រើប្រាស់នៃទ្រព្យសកម្មដែលបានរំពឹងទុក ត្រូវបានវាយតម្លៃដោយយោងទៅសមត្ថភាពបានរំពឹងទុក ឬសមិទ្ធផលជាក់ស្តែង។

ខ- ការខូចខាតរូបធាតុបានរំពឹងទុក ដែលអាស្រ័យលើកត្តាកិច្ចប្រតិបត្តិការ ដូចជាចំនួននៃវេន ដែលទ្រព្យសកម្មនឹងត្រូវបានប្រើប្រាស់និងកម្មវិធីជួសជុលនិងថែទាំនៃទ្រព្យសកម្មនៅពេលទំនេរ។

គ- ភាពហួសសម័យនៃពាណិជ្ជកម្ម ឬបច្ចេកវិទ្យា ដែលកើតឡើងពីការប្រែប្រួល ឬការធ្វើឲ្យប្រសើរឡើងនៅក្នុងផលិតកម្ម ឬពីការប្រែប្រួលក្នុងតម្រូវការទីផ្សារ សម្រាប់ផលិតផល ឬសេវាកម្មនៃទ្រព្យសកម្ម ។

ឃ- ការកំរិតតាមច្បាប់ ឬស្រដៀងគ្នា លើការប្រើប្រាស់ទ្រព្យសកម្ម ដូចជាកាលបរិច្ឆេទផុតកំណត់ នៃភតិសន្យាពាក់ព័ន្ធ ។

៥៧- អាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម គឺត្រូវបានកំណត់ក្នុងលក្ខខណ្ឌការប្រើប្រាស់បានរំពឹងទុកនៃទ្រព្យសកម្មចំពោះអង្គភាព។ គោលនយោបាយគ្រប់គ្រងទ្រព្យសកម្មរបស់អង្គភាពអាចពាក់ព័ន្ធទៅនឹងការលក់ចោលនៃទ្រព្យសកម្មបន្ទាប់ពីពេលជាក់លាក់ ឬបន្ទាប់ពីប្រើប្រាស់នៃសមាមាត្រជាក់លាក់នៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលមានក្នុងទ្រព្យសកម្ម។ ដូច្នេះហើយ អាយុកាលប្រើប្រាស់នៃ ទ្រព្យសកម្មអាចមានរយៈពេលខ្លីជាងអាយុកាល

សេដ្ឋកិច្ច ។ ការប៉ាន់ស្មាននៃអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម គឺជាបញ្ហានៃការវិនិច្ឆ័យ ដែលផ្អែកលើបទពិសោធន៍របស់អង្គភាព ជាមួយនិងទ្រព្យសកម្មស្រដៀង ។

៥៨- ដី និងអគារ គឺជាទ្រព្យសកម្មដាច់ដោយឡែក ហើយត្រូវបានធ្វើគណនេយ្យកម្ម ដាច់ដោយឡែកដែរ ទោះជាពួកវាត្រូវបានទិញរួមគ្នាក៏ដោយ ។ ជាមួយនិងករណីលើកលែងមួយចំនួន ដូចជាទីកន្លែងយកថ្ម និងការដ្ឋានប្រើប្រាស់ការចាក់បំពេញដី ដីមានរយៈពេលប្រើប្រាស់មិនកំណត់ ហើយហេតុដូច្នេះ មិនត្រូវបានធ្វើរំលស់ឡើយ។ អគារមានរយៈពេលប្រើប្រាស់កំណត់ហេតុដូច្នេះ អគារជាទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ។ ការកើនឡើងតម្លៃដី ដែលអគារមាននៅពីលើ មិនជះឥទ្ធិពលដល់ការគណនាទឹកប្រាក់រំលស់អគារឡើយ ។

៥៩- ប្រសិនបើថ្លៃដើមដី រួមបញ្ចូលថ្លៃដើមនៃការរុះរើការដ្ឋាន ការផ្លាស់ប្តូរ និងការរៀបចំឡើងវិញ ផ្នែកនៃដីនោះ គឺត្រូវបានរំលស់លើការិយបរិច្ឆេទនៃអត្ថប្រយោជន៍ ដែលបានទទួលបានតាមការបង្កើតមានថ្លៃដើមទាំងអស់នោះ។ ក្នុងករណីខ្លះ ដីខ្លួនវា អាចមានរយៈពេលប្រើប្រាស់កំណត់ដែរ ដែលវាត្រូវបានធ្វើរំលស់ តាមលក្ខណៈដែលឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍ដែលនឹងកើតមានពីវា ។

## **វិធីសាស្ត្ររំលស់**

៦០- **វិធីសាស្ត្ររំលស់ដែលត្រូវបានប្រើប្រាស់ត្រូវឆ្លុះបញ្ចាំងពីគំរូដែលអត្ថប្រយោជន៍សេដ្ឋកិច្ច អនាគតត្រូវបានគេរំពឹងទុកថានឹងត្រូវបានប្រើប្រាស់ដោយអង្គភាព ។**

**៦១- វិធីសាស្ត្ររំលស់ ដែលបានអនុវត្តចំពោះទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញយ៉ាងហោចណាស់ រាល់ចុងឆ្នាំហិរញ្ញវត្ថុនីមួយៗប្រសិនបើមានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគំរូបានរំពឹងទុកនៃការប្រើប្រាស់នៃ អត្ថប្រយោជន៍ សេដ្ឋកិច្ចអនាគតដែលមាននៅក្នុងទ្រព្យសកម្មវិធីសាស្ត្រត្រូវបានផ្លាស់ប្តូរដើម្បីឆ្លុះបញ្ចាំងពីគំរូប្រែប្រួល ។ ការប្រែប្រួលបែបនេះត្រូវបានធ្វើគណនេយ្យកម្មជាការផ្លាស់ប្តូរក្នុងការប៉ាន់ស្មាន គណនេយ្យដោយអនុលោមតាម ស.គ.អ.ក ៨ ។**

៦២- វិធីសាស្ត្ររំលស់ផ្សេងគ្នា អាចត្រូវបានគេប្រើប្រាស់ដើម្បីបែងចែកទឹកប្រាក់រំលស់អាចរំលស់បាននៃទ្រព្យ សកម្មតាមមូលដ្ឋានជាប្រព័ន្ធ លើរយៈពេលប្រើប្រាស់របស់វា។ វិធីសាស្ត្រទាំងនេះ រួមបញ្ចូលទាំងវិធីសាស្ត្រថេរ វិធីសាស្ត្រសមតុល្យថយចុះ និងវិធីសាស្ត្រឯកតាផលិតកម្ម។ រំលស់ថេរផ្តល់ឲ្យមានបន្ទុកថេរលើរយៈពេលប្រើប្រាស់ ប្រសិនបើតម្លៃកាកសំណល់របស់ទ្រព្យសកម្មមិនប្រែប្រួល ។ វិធីសាស្ត្រសមតុល្យថយចុះផ្តល់ឲ្យមានការបន្ទុកថយចុះលើរយៈពេលប្រើប្រាស់។ វិធីសាស្ត្រឯកតាផលិតកម្មផ្តល់ឲ្យមានបន្ទុកផ្អែកលើការប្រើប្រាស់ ឬសមិទ្ធិផល ។ អង្គភាពជ្រើសរើសវិធីសាស្ត្រ ដែលឆ្លុះបញ្ចាំងពីគំរូបានរំពឹងទុកនៃការប្រើប្រាស់ នៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលមានក្នុងទ្រព្យសកម្ម។ វិធីសាស្ត្រនោះត្រូវបានគេអនុវត្តប្រកបដោយសង្គតិភាពពីការិយបរិច្ឆេទមួយទៅមួយ លើកលែងតែមានការប្រែប្រួលក្នុងគំរូបានរំពឹងទុកនៃ ការប្រើប្រាស់នៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតទាំងនោះ ។

## ការខាតពីការធ្លាក់ចុះនៃតម្លៃ

៦៣- ដើម្បីកំណត់ថាតើធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារត្រូវបានធ្លាក់ចុះតម្លៃ អង្គភាពមួយត្រូវអនុវត្តតាម ស.គ.អ.ក ៣៦ ការធ្លាក់ចុះតំលៃនៃទ្រព្យសកម្ម។ ស្តង់ដានោះពន្យល់ពីរបៀបដែលអង្គភាពមួយពិនិត្យឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មរបស់ខ្លួន ពីរបៀបដែលអង្គភាពកំណត់ទឹកប្រាក់ស្រង់មកវិញនៃ ទ្រព្យសកម្ម និងពីពេលវាដែលអង្គភាពទទួលស្គាល់ ឬបញ្ច្រាស់ការទទួលស្គាល់ នៃការខាតពីការធ្លាក់ចុះតម្លៃ ។

៦៤- [លុបចោល]

## តម្លៃតបស្នងចំពោះការខូចខាត

៦៥- តម្លៃតបស្នងពីភាគីទី៣ សម្រាប់ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារដែលត្រូវបានធ្វើឱ្យខូចខាតធ្វើឱ្យបាត់បង់ ឬបោះបង់ចោលត្រូវបានដាក់ចូលក្នុងរបាយការណ៍ចំណេញ ឬ ខាតនៅពេលតម្លៃតបស្នងក្លាយជាគណនីត្រូវទទួល ។

៦៦- ការខូចខាត ឬបាត់បង់នៃធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារការទាមទារដែលទាក់ទិន ឬទូទាត់នៃតំលៃតបស្នងពីភាគីទី៣ និងការទិញ ឬសាងសង់ក្រោយៗ មកទៀតនៃទ្រព្យសកម្មជំនួស គឺជាព្រឹត្តិការណ៍សេដ្ឋកិច្ចដាច់ដោយឡែក និងត្រូវបានធ្វើគណនេយ្យកម្មដាច់ដោយឡែក ដូចខាងក្រោម ÷

ក- ការខូចខាតនៃធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារត្រូវបានទទួលស្គាល់ដោយអនុលោមតាម ស.គ.អ.ក ៣៦ ។

ខ- ការឈប់ទទួលស្គាល់នៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវបានឈប់ប្រើ ឬ លក់ចេញត្រូវបានកំណត់តាមស្តង់ដានេះ។

គ- តំលៃតបស្នងពីភាគីទី ៣ សម្រាប់ធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវបានខូចខាតត្រូវបានបាត់បង់ ឬត្រូវបានបោះចោលត្រូវបានដាក់បញ្ចូលក្នុងការកំណត់ចំណេញឬខាតនៅពេលវាក្លាយជា គណនេយ្យត្រូវទទួល ។

ឃ- ថ្លៃដើមនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដែលត្រូវរៀបចំឡើងវិញត្រូវបានទិញ ឬត្រូវបានសាងសង់ជាការជំនួសគឺត្រូវបានកំណត់តាមស្តង់ដានេះ ។

## ការឈប់ទទួលស្គាល់

**៦៧- តម្លៃយោងនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានឈប់ទទួលស្គាល់÷**

**ក- នៅពេលលក់ចោល ឬ**

**ខ- នៅពេលគ្មានអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតត្រូវបានរំពឹងទុកពីការប្រើប្រាស់វា ឬ លក់ ។**

**៦៨- ចំណេញ ឬខាតដែលកើតឡើងពីការឈប់ទទួលស្គាល់នៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានដាក់បញ្ចូលក្នុងចំណេញ ឬខាត នៅពេលធាតុនោះ ត្រូវបានឈប់ទទួលស្គាល់ (លើកលែង ស.គ.អ.ក ១៧ បានតម្រូវបើមិនដូច្នោះទេ នៅពេលលក់ ឬ ភតិសន្យាត្រឡប់វិញ )។ ចំណេញមិនត្រូវបានចាត់ថ្នាក់ជាផលរបរឡើយ ។**

៦៨ក ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណើរសកម្មភាពប្រក្រតី អង្គភាពមួយលក់ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារ ដែលអង្គភាពបានរក្សាទុកសំរាប់

ជួលទៅឲ្យអ្នកផ្សេងទៀត ត្រូវផ្ទេរទ្រព្យសកម្មបែបនេះ ទៅជាសន្និធិតាមតំលៃយោងនៅពេលដែលទ្រព្យសកម្ម ទាំងនេះត្រូវបានឈប់ជួល ហើយប្រែក្លាយវាជាការរក្សាទុកសំរាប់លក់វិញ។ ចំណូលពីការលក់ទ្រព្យសកម្មបែបនេះត្រូវបានទទួលស្គាល់ជាផលរបរដោយអនុលោម តាម ស.គ.អ.ក ១៨ *ផលចំណូល*។ ស.រ.ហ.អ.ក ៥ មិនអនុវត្តទេនៅពេលដែលទ្រព្យសកម្មត្រូវបានរក្សាទុកសំរាប់លក់នៅក្នុងដំណើរអាជីវកម្មប្រក្រតីត្រូវបានផ្ទេរទៅសន្និធិ ។

៦៩- ការបោះបង់ចោលធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារអាចកើតឡើងតាមមធ្យោបាយជាច្រើន (ឧទាហរណ៍ ដោយលក់ដោយជួល ឬធ្វើអំណោយ ) ។ ក្នុងការកំណត់កាលបរិច្ឆេទលក់នៃ ធាតុមួយនោះ អង្គភាពអនុវត្តគោលការណ៍ក្នុង ស.គ.អ.ក ១៨ ផលចំណូល សម្រាប់ការទទួលស្គាល់ចំណូលពីការលក់ទំនិញ ។ ស.គ.ក ១៧ អនុវត្តការបោះបង់ចោលដោយការលក់ និងភតិសន្យាត្រឡប់វិញ ។

៧០- ប្រសិនបើ តាមគោលការណ៍ទទួលស្គាល់ក្នុងកថាខណ្ឌ ៧ អង្គភាពមួយទទួលស្គាល់ក្នុងតម្លៃយោងនៃធាតុទ្រព្យរោងចក្រ និងបរិក្ខារនូវថ្លៃដើមនៃការជំនួសសម្រាប់ផ្នែកនៃធាតុនោះ បន្ទាប់មកអង្គភាពឈប់ទទួលស្គាល់តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសដោយមិនគិតថា តើផ្នែកជំនួសត្រូវបានរំលស់ដាច់ដោយឡែកឬទេ ។ ប្រសិនបើវាអាចអនុវត្តបានសម្រាប់អង្គភាព ដើម្បីគណនាតម្លៃយោងនៃផ្នែកជំនួសអង្គភាពអាចប្រើប្រាស់ថ្លៃដើមនៃការជំនួសជា ការចង្អុលបង្ហាញនៃអ្វីដែលថ្លៃដើមនៃផ្នែកជំនួស នៅពេលនោះត្រូវបានទិញ ឬសាងសង់ ។

**៧១- ចំណេញ ឬ ខាតដែលកើតឡើងពីការឈប់ទទួលស្គាល់នៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានគេកំណត់ជាភាពខុសគ្នារវាងចំណូលបោះបង់ចោលពិត (ប្រសិនបើមាន) និង តម្លៃយោងនៃធាតុនោះ។**

៧២- តម្លៃតបស្នងដែលនឹងទទួលពីការបោះបង់ចោលនៃទ្រព្យរោងចក្រ និង បរិក្ខារ គឺត្រូវបានគេទទួលស្គាល់ជាលើកដំបូងតាមតម្លៃសមស្របរបស់វា។ ប្រសិនបើការទូទាត់សម្រាប់ធាតុនោះ គឺត្រូវបានពន្យាតម្លៃតបស្នងដែលបានទទួលត្រូវបានស្គាល់ជាលើកដំបូងតាមតម្លៃសមមូលសាច់ប្រាក់ ។ ភាពខុសគ្នា រវាងទឹកប្រាក់នៃតម្លៃតបស្នងតែនាម និងតម្លៃសាច់ប្រាក់សមមូលត្រូវបានទទួលស្គាល់ ជាចំណូលការប្រាក់ដោយអនុលោមតាម ស.គ.អ.ក ១៨ ដោយឆ្លុះបញ្ចាំងពីចំណូលលើគណនីត្រូវទទួល ។

## ការលាតត្រដាងព័ត៌មាន

**៧៣- របាយការណ៍ហិរញ្ញវត្ថុ ត្រូវលាតត្រដាងបង្ហាញ សម្រាប់ថ្នាក់នីមួយៗនៃទ្រព្យ រោងចក្រ និង បរិក្ខារៈ**

**ក- មូលដ្ឋានវាស់វែង ដែលត្រូវបានប្រើសម្រាប់គណនាតម្លៃយោងដុល។**

**ខ- វិធីសាស្ត្ររំលស់ដែលត្រូវបានប្រើ។**

**គ- អាយុកាលប្រើប្រាស់ ឬអត្រារំលស់ដែលប្រើ។**

**ឃ- តម្លៃយោងដុល និងរំលស់បូកបន្ត (ដែលសរុបជាមួយការខាតបង់បូកបន្ត) នៅដើម និងចុងការិយបរិច្ឆេទ និង**

**ង- ការសម្របសម្រួលនៃតម្លៃយោងនៅដើម និងចុងការិយបរិច្ឆេទដែលបង្ហាញៈ**

**១- ការបន្ថែម ។**

២- ទ្រព្យសកម្ម ដែលត្រូវចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ឬដែលត្រូវដាក់បញ្ចូលក្នុងបណ្តុំក្រុមហ៊ុនលក់ ដែលចាត់ថ្នាក់សម្រាប់លក់តាម ស.រ.ហ.អ.ក ៥ និង ការលក់ផ្សេងទៀត ។

៣- ការទិញតាមរយៈការរួមពាណិជ្ជកម្មបញ្ចូលគ្នា ។

៤- ការកើន ឬថយដោយសារការវាយតម្លៃឡើងវិញតាមកថាខណ្ឌ ៣១ ៣៩ និង ៤០ និងពីការខាតបង់ដែលត្រូវបានទទួលស្គាល់ ឬបញ្ច្រាស់នៅក្នុងចំណូលលម្អិតផ្សេងទៀតអនុលោមតាម ស.គ.អ.ក ៣៦ ។

៥- ការខាតបង់ ដែលត្រូវបានទទួលស្គាល់ ក្នុងចំណេញ ឬខាតតាម ស.គ.អ.ក ៣៦ ។

៦- ការខាតបង់ ដែលត្រូវបញ្ច្រាស់វិញក្នុងប្រាក់ចំណេញ ឬខាត តាម ស.គ.អ.ក ៣៦ ។

៧- រំលស់។

៨- ភាពខុសគ្នាពិតពីការប្តូរប្រាក់ដែលកើតឡើងលើការប្រែសំរួលរបាយការណ៍ហិរញ្ញវត្ថុ ពីរូបិយបណ្ណមុខងារទៅជារូបិយសំរាប់បង្ហាញផ្សេងទៀត រួមបញ្ចូលការប្រែសម្រួលប្រតិបត្តិការក្រៅប្រទេសទៅជារូបិយបណ្ណ សំរាប់បង្ហាញរបស់អង្គភាពរាយការណ៍ ។

៩- ការប្រែប្រួលផ្សេងទៀត ។

៧៤- របាយការណ៍ហិរញ្ញវត្ថុ ក៏ត្រូវបង្ហាញ ÷

ក- អត្ថិភាព និងទឹកប្រាក់នៃការកំហិតលើកម្មសិទ្ធិ និងទ្រព្យរោងចក្រ និងបរិក្ខារដែលត្រូវដាក់បញ្ចាំសម្រាប់ធានាបំណុល ។

ខ- ទឹកប្រាក់ចំណាយ ដែលត្រូវបានទទួលស្គាល់ក្នុងតម្លៃយោងនៃធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារនៅពេលសាងសង់ដោយខ្លួនឯង ។

គ- ទឹកប្រាក់នៃការធានាតាមកិច្ចសន្យាសម្រាប់ការទិញទ្រព្យ រោងចក្រ និងបរិក្ខារ។

ឃ- ប្រសិនបើមិនត្រូវបានលាតត្រដាងដាច់ដោយឡែកលើរបាយ-ការណ៍លទ្ធផលលម្អិតទេនោះ ទឹកប្រាក់នៃតម្លៃតបស្នងពីភាគីទី៣ សម្រាប់ធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារដែលត្រូវបានខាតបង់ ត្រូវបានបាត់បង់ ឬបោះចោលដែលត្រូវបានដាក់បញ្ចូលក្នុងចំណេញ ឬខាត។

៧៥- ការជ្រើសរើសនៃវិធីសាស្ត្ររំលស់ និងការប៉ាន់ស្មានពីរយៈពេលប្រើប្រាស់ទ្រព្យសកម្ម គឺជាកិច្ចការនៃការវិនិច្ឆ័យ។ ហេតុដូច្នេះការការលាតត្រដាងពីវិធីសាស្ត្រ ដែលត្រូវបានអនុម័ត និងរយៈពេលប្រើប៉ាន់ស្មាន ឬអត្រារំលស់ ផ្តល់ឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនូវព័ត៌មាន ដែលអាចឱ្យពួកគេពិនិត្យមើលគោលនយោបាយ ដែលត្រូវបានជ្រើសរើសដោយគណៈគ្រប់គ្រង និងអាចធ្វើឱ្យពួកគេប្រៀបធៀបជាមួយនឹងអង្គភាពផ្សេងទៀត។ សម្រាប់ហេតុផលស្រដៀងគ្នា វាចាំបាច់ដើម្បីពន្យល់បង្ហាញៈ

ក- រំលស់ ថាតើបានទទួលស្គាល់ក្នុងចំណេញ ឬខាតឬជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មផ្សេងទៀតក្នុងកំឡុងការិយបរិច្ឆេទ និង

ខ- រំលស់បូកបន្ត នៅចុងការិយបរិច្ឆេទ។

៧៦- យោងតាម ស.គ.អ.ក ៨ អង្គភាពលាតត្រដាងពីលក្ខណៈ និងផលប៉ះពាល់នៃការប្រែប្រួលក្នុងការប៉ាន់ស្មានគណនេយ្យ ដែលមានផលប៉ះពាល់ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ឬត្រូវបានគេរំពឹងទុកថាមានផលប៉ះពាល់ ក្នុងការិយបិរច្ឆេទក្រោយៗទៀត។ សម្រាប់ទ្រព្យរោងចក្រ និងបរិក្ខារ ការលាតត្រដាងបែបនេះ អាចកើតឡើងពីការប្រែប្រួលក្នុងការប៉ាន់ស្មាន ទាក់ទងទៅនឹងៈ

ក- តម្លៃកាកសំណល់

ខ- ថ្លៃដើមប៉ាន់ស្មាននៃការរុះរើ ការផ្លាស់ប្តូរ ឬរៀបឡើងវិញនៃទ្រព្យរោងចក្រ និងបរិក្ខារ។

គ- រយៈពេលប្រើប្រាស់។

ឃ- វិធីសាស្រ្តរំលស់។

**៧៧- ប្រសិនបើធាតុនៃទ្រព្យរោងចក្រ និងបរិក្ខារត្រូវបានបង្ហាញតាមទឹកប្រាក់វាយតម្លៃឡើងវិញ ខាងក្រោមត្រូវលាតត្រដាងបង្ហាញ÷**

**ក- កាលបរិច្ឆេទវាយតម្លៃឡើងវិញ**

**ខ- ថាតើអ្នកវាយតម្លៃឯករាជ្យ ត្រូវបានពាក់ព័ន្ធឬទេ?**

**គ- វិធីសាស្រ្ត និងវិធីសន្មតសំខាន់ៗ ដែលត្រូវបានអនុវត្ត ក្នុងការប៉ាន់ស្មានតម្លៃសមស្របរបស់ធាតុនោះ។**

**ឃ- ទំហំដែលតម្លៃសមស្របនៃធាតុនោះ ត្រូវបានគណនាដោយផ្ទាល់ដោយយោងលើថ្លៃអង្កេតក្នុងទីផ្សារ ឬប្រតិបត្តិការទីផ្សារបច្ចុប្បន្ន**

តាមប្រតិបត្តិការធម្មតា ឬត្រូវប៉ាន់ស្មានដោយប្រើប្រាស់បច្ចេក-ទេសវាយតម្លៃផ្សេងទៀត។

ង- សម្រាប់ថ្នាក់ដែលត្រូវបានវាយតម្លៃនីមួយៗនៃទ្រព្យរោងចក្រ និងបរិក្ខារតម្លៃយោងត្រូវបានគេទទួលស្គាល់ដែលទ្រព្យសកម្ម ត្រូវបានបង្ហាញតាមវិធីសាស្ត្រថ្លៃដើម និង

ច- អតិរេកពីការវាយតម្លៃឡើងវិញ ដោយចង្អុលបង្ហាញពីការប្រែប្រួលសម្រាប់ការិយបរិច្ឆេទ និងការកម្រិតណាមួយលើការបែងចែកសមតុល្យឱ្យម្ចាស់ភាគហ៊ុន។

៧៨- យោងតាម ស.គ.អ.ក ៣៦អង្គភាពលាតត្រដាបង្ហាញព័ត៌មានពីទ្រព្យរោងចក្រ និងបរិក្ខារខាតបង់បន្ថែមលើព័ត៌មាន ដែលតម្រូវដោយកថាខណ្ឌ ៧៣ (ង)( ៤)-(៦)។

៧៩- អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ក៏អាចស្វែងរកព័ត៌មានពាក់ព័ន្ធខាងក្រោមដែលពាក់ព័ន្ធនឹងតម្រូវការរបស់ពួកគេៈ

ក- តម្លៃយោងនៃទ្រព្យ រោងចក្រ និងបរិក្ខារទំនេរបណ្តោះអាសន្ន។

ខ- តម្លៃយោងដុលនៃទ្រព្យរោងចក្រ និងបរិក្ខារដែលត្រូវបានរំលស់ទាំងស្រុងតែនៅតែប្រើ។

គ- តម្លៃយោងនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលត្រូវបានដកចេញពីការប្រើប្រាស់ និងមិនចាត់ថ្នាក់រក្សាទុកសម្រាប់លក់ ដោយអនុលោម តាម ស.រ.ហ.អ.ក ៥ និង

ឃ- ពេលវេលាដែលវិធីសាស្ត្រថ្លៃដើមត្រូវបានប្រើ តម្លៃសមស្របនៃទ្រព្យរោងចក្រ និងបរិក្ខារ នៅពេលវាមានភាពខុសគ្នាជាសារវ័ន្តពីតម្លៃយោង។

ហេតុដូច្នេះ អង្គភាពត្រូវបានលើកទឹកចិត្តឱ្យលាតត្រដាងបង្ហាញទឹកប្រាក់ទាំងនេះ ។

## អន្តរបញ្ញត្តិ

៨០- សេចក្តីតំរូវនៃកថាខណ្ឌ ២៤ - ២៦ ទាក់ទងនឹងការវាស់វែងលើកដំបូងនៃធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខារដែលបានទិញក្នុងប្រតិបត្តិការដោះដូរទ្រព្យសកម្មត្រូវបានអនុវត្តតាមវិធីសាស្រ្តទៅពេលអនាគត ចំពោះប្រតិបត្តិការអនាគត។

## កាលបរិច្ឆេទចូលធរមាន

៨១- អង្គភាព ត្រូវអនុវត្តស្តង់ដានេះ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែ មករា ឆ្នាំ ២០០៥។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាពអនុវត្តស្តង់ដានេះសម្រាប់ការិយបរិច្ឆេទ ដែលចាប់ផ្តើមមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ វាត្រូវលាតត្រដាងបង្ហាញសាច់រឿងនោះ។

៨១ក-អង្គភាព ត្រូវអនុវត្តវិសោធនកម្មក្នុង កថាខណ្ឌ ៣ សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬបន្ទាប់ ថ្ងៃទី១ ខែមករា ២០០៥។ ប្រសិនបើអង្គភាពអនុវត្ត ស.រ.ហ.អ ៦ សម្រាប់ការិយបិរច្ឆេទដើម វិសោធនកម្មទាំងនោះត្រូវបានគេអនុវត្តសម្រាប់ការិយបរិច្ឆេទដើមនោះ ។

៨១ខ ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (ដូចបានកែប្រែក្នុងឆ្នាំ ២០០៧) បានធ្វើវិសោធនកម្មលើវាក្យស័ព្ទដែលត្រូវបានប្រើ ក្នុងគ្រប់ ស.រ.ហ.អ.ក ។ លើសពីនេះទៅទៀត វាធ្វើវិសោធនកម្មកថាខណ្ឌ ៣៩

៤០ និង៧៣ (ង) (៤) ។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្មសំរាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយអនុវត្តតាម ស.គ.អ.ក ១ (កែប្រែ ឆ្នាំ២០០៧) សំរាប់ការិយបរិច្ឆេទដើម នោះវិសោធនកម្មត្រូវបានអនុវត្តសំរាប់ការិយបរិច្ឆេទដើមនោះ ។

៨១គ ស.រ.ហ.អ.ក ៣ *ការបញ្ចូលអាជីវកម្មរួមគ្នា* (ដូចបានកែប្រែក្នុងឆ្នាំ២០០៨) បានធ្វើវិសោធនកម្ម កថាខណ្ឌ ៤៤។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះសំរាប់កាលរិយច្ឆេទប្រចាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយប្រើ ស.រ.ហ.អ.ក ៣ (កែប្រែ ឆ្នាំ២០០៨) សំរាប់ការិយបរិច្ឆេទដើម វិសោធនកម្មក៏ត្រូវបានប្រើសំរាប់ការិយបរិច្ឆេទដើមនោះ ។

៨១ឃ កថាខណ្ឌ ៦ និង ៦៩ ត្រូវបានធ្វើវិសោធនកម្ម និងកថាខណ្ឌ ៦៨ក ត្រូវបានបន្ថែម ដោយ*ការធ្វើឲ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* បានចេញផ្សាយនៅក្នុង ខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទាំងនោះសំរាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុន ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាពមួយ អនុវត្តវិសោធនកម្មសំរាប់ការិយបរិច្ឆេទដើម អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ និងនៅពេលដូចគ្នាត្រូវអនុវត្តវិសោធនកម្មទាក់ទិននឹង ស.គ.អ.ក ៧ *របាយការណ៍លំហូរសាច់ប្រាក់*។

៨១ង កថាខណ្ឌ ៥ ត្រូវបានធ្វើវិសោធនកម្មដោយ *ការធ្វើឲ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុង ខែឧសភា ឆ្នាំ២០០៨ ។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្មនោះទៅពេលអនាគត សំរាប់ការិយ-

បរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាតប្រសិនបើអង្គ ភាពមួយក៏ត្រូវ អនុវត្តវិសោធនកម្មចំពោះកថាខណ្ឌ ៨ ៩ ២២ ៤៨ ៥៣ ៥៣ក ៥៤ ៥៧ និង ៨៥ខ នៃ ស.គ.អ.ក ៤០ នៅពេលដូចគ្នា។ ប្រសិនបើអង្គភាពមួយ អនុវត្តវិសោធនកម្មសំរាប់គ្រាដើម អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍ នោះ ។

## ការដកចេញនៃសេចក្តីប្រកាសផ្សេងៗ

៨២- ស្តង់ដានេះជំនួស ស.គ.ក ១៦ ទ្រព្យ រោងចក្រ និងបរិក្ខារ (ទ្រព្យ រោងចក្រ និងបរិក្ខារ) ដែលត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០០៣ ។

៨៣- ស្តង់ដានេះ ជំនួសការបកស្រាយខាងក្រោមៈ

ក- គ.ប.ស -៦ ថ្លៃដើមនៃការកែប្រែផ្នែកទុនដែលមានស្រាប់។

ខ- គ.ប.ស-១៤ ទ្រព្យរោងចក្រ និងបរិក្ខារតបស្នងសម្រាប់ការខាត បង់ ឬបាត់បង់ធាតុនោះ ។

គ- គ.ប.ស-២៣ ទ្រព្យរោងចក្រ និងបរិក្ខារការពិនិត្យសំខាន់ៗ ឬ ថ្លៃដើមជួសជុលធំៗ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ